# យុត្តិធម៌ និងអំពើពុករលួយនៅតុលាការខ្មែរក្រហម

យុត្តិធម៌នៅប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់ម្តងទៀត បន្ទាប់ពីការផ្សព្វផ្សាយពេលថ្មីៗនេះអំពីការត្រួតពិនិត្យយ៉ាងខ្លាំងទៅលើរឿងរ៉ាវកើតឡើងនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការត្រួតពិនិត្យធ្វើឡើងដោយកម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិ (UNDP) ដែលផ្តល់ថវិកា ៦,៤ លានដុល្លារអាមេរិកសម្រាប់តុលាការ បានចោទប្រកាន់ពីការរើសបុគ្គលិកមិនសមស្របនៅអង្គជំនុំជម្រះ, ការបង្កើនប្រាក់បៀវត្សដោយមិនសមហេតុផល និងការគ្រប់គ្រងមិនល្អកើតមាននៅអង្គជំនុំជម្រះ ។ ការសន្និដ្ឋានរបស់អ្នកត្រួតពិនិត្យធ្វើឡើងដោយមិនមុតមាំថា ប្រសិនបើតុលាការនេះមិនធ្វើការកែទម្រង់ឲ្យបានត្រឹមត្រូវ UNDP នឹងពិចារណាលើការដកខ្លួនចេញពីដំណើរការកាត់ទោសនេះ ។ មន្ត្រីកម្ពុជាទទួលស្គាល់កំហុស ប៉ុន្តែអះអាងថាកំហុសទាំងនោះមិនធ្វើឲ្យប៉ះពាល់ដល់ដំណើរការតុលាការទាំងមូលនោះទេ ។ បន្ទាប់ការចរចាមួយទស្សវត្សរ៍ពោរពេញដោយការលំបាក មន្ត្រីអន្តរជាតិក៏មិនគិតគូរខ្លាំងដល់ការត្រឡប់ទៅកិច្ចចរចាជាថ្មីឡើងវិញ ដែលនឹងពន្យារពេលដល់ការរកយុត្តិធម៌ជាថ្មីម្តងទៀត ។

នៅអំឡុងពេលចរចាអំពីតុលាការនេះ ខ្ញុំ និងបុគ្គលផ្សេងទៀត បានអះអាងថាសហគមន៍អន្តរជាតិមិនគួរគិតទៅដល់ភាពល្អឥតខ្ចោះ ដែលអាចបាត់បង់រឿងល្អនោះទេ ។ តុលាការចម្រុះមួយនឹងមានការលំបាកក្នុងការគ្រប់គ្រង ហើយចៀសមិនផុតពីមានភាពតានតឹង និងការប៉ះទង្គិចគ្នាដោយថាហេតុរវាងមន្ត្រីអង្គការសហប្រជាជាតិ និងមន្ត្រីក្នុងស្រុក ។ មន្ត្រីអង្គការសហប្រជាជាតិមានការខ្វះខាតចំណេះដឹងលម្អិត និងភាសារបស់កម្ពុជា ចំណែកឯមន្ត្រីក្នុងស្រុកវិញខ្វះចំណេះដឹងខាងច្បាប់អន្តរជាតិ ។ វាក៏មានការលំបាកផងដែរក្នុងការភ្ជាប់ច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ និងនីតិវិធីច្បាប់កម្ពុជា និងនីតិវិធីច្បាប់អន្តរជាតិ ។ ជាសង្ខេបមក តុលាការចម្រុះរវាងជាតិ និងអន្តរជាតិវានឹងមិនធ្វើតាមច្បាប់ "យ៉ាងខ្ជាប់ខ្ជួន" ឬក៏មានប្រសិទ្ធភាពដូចតុលាការអន្តរជាតិនៅទីក្រុងឡាអេនោះទេ ប៉ុន្តែវាជាការថ្លឹងថ្លែងមួយក្នុងការគិតទៅដល់វិធីផ្សេងៗដើម្បីសម្រេចគោលបំណងយុត្តិធម៌ ការផ្សះផ្សា និងការអភិវឌ្ឍ ។

បើពិនិត្យលើទិដ្ឋភាពជារួម អង្គជំនុំជម្រះបានបន្តដំណើរការរបស់ខ្លួនយ៉ាងមុតមាំដើម្បីនាំយកចុងចោទសំខាន់ៗមកកាន់សវនាការ ។ ដូចដែលបានរំពឹងទុក ប្រការនេះធ្វើមិនឲ្យមានការកើនឡើងនូវការឈឺចាប់ថែមទៀត ។ សំខាន់ជាងនេះទៅទៀតនោះ ភាគច្រើនរឿងរ៉ាវទាំងនេះមិនមែនជាឧបសគ្គដល់សុចរិតភាពជាមូលដ្ឋានរបស់ដំណើរការនេះឡើយ ។ ឧទាហរណ៍ ការចេញបញ្ជាឲ្យឃុំខ្លួនរបស់

Documentation Center of Cambodia
Searching for the Truth ស្វែងរកការពិត ដើម្បីការចងចាំ និង យុត្តិធម៌
DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

តុលាការលើ ឌុច និង នួន ជា បន្តប់ន័យមិនច្បាស់លាស់ មួយផ្នែកផ្អែកលើការអនុវត្តគោលការណ៍ប្រព័ន្ធច្បាប់ខុសគ្នា ។ ភាសាបីប្រើប្រាស់ជាផ្លូវការសព្វថ្ងៃគឺភាសាខ្មែរ អង់គ្លេស និងបារាំង ដោយថាហេតុគេចមិនផុតពីកំហុស និងអសមត្ថភាពក្នុងការបកប្រែ ។ ការិយាល័យរដ្ឋបាលរបស់អង្គជំនុំជម្រះមិនទាន់បានបង្កើតយន្តការគ្រប់គ្រាន់ក្នុងការចែកផ្សាយឯកសារដល់មន្ត្រីតុលាការដែលពាក់ព័ន្ធនៅឡើយទេ ។ ការតែងតាំងក្នុងពេលជាមួយគ្នានេះលើចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង ជាប្រធានសាលាឧទ្ធរណ៍ធ្វើឲ្យមានបញ្ហាចោទឡើងទាក់ទងនឹងទំនាស់ផលប្រយោជន៍ ។ តែទោះបីជាយ៉ាងណាក៏ដោយក៏រឿងរ៉ាវបែបនេះ វានឹងមិនធ្វើឲ្យប៉ះពាល់ដល់ដំណើរការចាប់ផ្តើមតុលាការថ្មីមួយនេះដែរ ។

អំពើពុករលួយគឺជារឿងផ្សេងពីនេះ ។ ការប្រើប្រាស់ថវិកាខុស ការផ្តល់សំណូក និងការប្រើប្រាស់ខ្សែបណ្តាញដើម្បីចូលធ្វើការ ទាំងអស់នេះមិនមែនជាប្រភេទ “មិនគ្រប់លក្ខណៈ” ដែលសហគមន៍អន្តរជាតិ និងសាធារណជនកម្ពុជាទូទៅ គិតថារឿងនេះជាការលំបាកក្នុងការគ្រប់គ្រងដំណើរការតុលាការចម្រុះ និងដំណើរការព្រហ្មទណ្ឌដែលមានភាពស្មុគស្មាញនោះទេ ។ ប្រសិនបើការចោទរបស់UNDPជាការពិត នោះគឺព្រោះតែមន្ត្រីខ្លះបានរំលោភអំណាចរបស់ខ្លួន ។ រដ្ឋាភិបាលកម្ពុជានិងសហគមន៍អ្នកផ្តល់ជំនួយ គួរតែអន្តរាគមន៍ជាបន្ទាន់ឲ្យមានគណៈកម្មាធិការពិសេសមួយ ឬស្ថាប័នស្រដៀងគ្នានេះដើម្បីស៊ើបអង្កេតការចោទប្រកាន់នេះបន្ថែមទៀត ។ អំពើពុករលួយនឹងធ្វើឲ្យខូចធ្ងន់ធ្ងរដល់សមត្ថភាពរបស់តុលាការក្នុងការធ្វើជាគំរូដល់នីតិរដ្ឋក្នុងប្រទេសកម្ពុជា ។ ហើយវាក៏ជាការប្រមាថធ្ងន់ធ្ងរមួយដល់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានរង់ចាំយុត្តិធម៌អស់រយៈពេលបីទសវត្សរ៍មកហើយ ។ ភាពពុករលួយបង្កឡើងដោយមន្ត្រីអង្គជំនុំជម្រះ ដែលខ្លួនឯងផ្ទាល់ក៏ជាជនរងគ្រោះពីរបបខ្មែរក្រហមដែរនោះ វានឹងជាការក្បត់មួយគួរឲ្យឈឺចាប់ណាស់ ។

ការបញ្ចប់អំពើពុករលួយក្នុងប្រព័ន្ធតុលាការ គឺជាគោលបំណងមួយដែលអង្គជំនុំជម្រះវិសាមញ្ញគួរតែស្វះស្វែងដើម្បីសម្រេចគោលបំណងនេះ ។ អំពើពុករលួយកើតឡើងជាធម្មតាទៅហើយនៅសង្គមកម្ពុជា ហើយវាមានការចូលរួមពីមនុស្សក្នុងស្រុក និងអន្តរជាតិ ហើយបានក្លាយជាផលប៉ះពាល់រាលដាលដល់អភិបាលកិច្ច និងការរីកលូតលាស់របស់ប្រទេស ។ អង្គការតម្លាភាពអន្តរជាតិក្នុងពេលថ្មីៗនេះ បានកំណត់ប្រទេសកម្ពុជាស្ថិតក្នុងចំណាត់ថ្នាក់ទី១៦២ ក្នុងចំណោមប្រទេសទាំង១៧៩ដែលមានអំពើពុករលួយច្រើនបំផុតនៅលើពិភពលោក ។ ក្នុងដំណើរទស្សនកិច្ចនៅប្រទេសកម្ពុជា ក្នុងពេលថ្មីៗនេះរបស់ប្រធានធនាគារពិភពលោក លោក រ៉ូប៊ែត ហ្ស៊ូលីក(Robert Zoellick) បានសង្កត់ធ្ងន់លើអំពើពុករលួយនេះ ដែលធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់គម្រោងអភិវឌ្ឍជាច្រើនក្នុងប្រទេសនេះ ។ អំពើពុករលួយ បន្ថយការជឿទុកចិត្តលើកិច្ចសន្យានិងសិទ្ធិលើទ្រព្យសម្បត្តិ បន្ថយការវិនិយោគបរទេសស្រប

ច្បាប់ និងបន្ទាក់ការអភិវឌ្ឍសេដ្ឋកិច្ច ហើយវាក៏ធ្វើឲ្យមានភាពអយុត្តិធម៌កើតមានឥតឈប់ឈរនៅថ្នាក់មូលដ្ឋាន ។ អង្គការហ្គោឡូបលវិណេស (Global Witness) បានចេញរបាយការណ៍ស្តីពីអំពើពុករលួយក្នុងការប្រមូលយកធនធានខុសច្បាប់ ដោយបានផ្តល់ភស្តុតាងចំពោះការរំលោភធ្វើឡើងលើសហគមន៍ប្រជាជនកម្ពុជាជនបទ និងបរិស្ថាន ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខទៀត អំពើពុករលួយនឹងធ្វើឲ្យបាត់បង់ចំណូលដល់ប្រជាជនកម្ពុជាសាមញ្ញលើការរកឃើញប្រេងកាតក្នុងពេលថ្មីៗនេះ ។

អំពើពុករលួយមិនត្រូវធ្វើឲ្យខូចខាតដល់តុលាការខ្មែរក្រហម ឬក៏ការអភិវឌ្ឍប្រទេសកម្ពុជាក្នុងពេលអនាគតឡើយ ។ វាជាការពិតណាស់ដែលរដ្ឋាភិបាលកម្ពុជាដើរតួនាទីសំខាន់ក្នុងការលុបបំបាត់បញ្ហានេះ ។ តុលាការខ្មែរក្រហមផ្តល់ឱកាសមួយក្នុងការបង្ហាញ ការធ្វើឲ្យប្រសើរឡើងរបស់រដ្ឋាភិបាលកម្ពុជាលើនយោបាយអភិបាលកិច្ច និងប្រព័ន្ធច្បាប់ ដែលនឹងទទួលបានកិត្តិនាម និងការវិនិយោគជាច្រើនទៀត ។ ភាពទន់ខ្សោយ និងបរាជ័យនៃដំណើរការអង្គជំនុំជម្រះ នឹងនាំមកនូវការបាត់បង់កេរ្តិ៍ឈ្មោះ និងបំផ្លាញដំហររបស់ប្រទេសនៅក្នុងតំបន់ និងការគ្រប់គ្រងស្របច្បាប់ជាសាធារណៈ ។

អ្នកផ្តល់ជំនួយសំខាន់ៗដល់តុលាការនេះ ក៏ត្រូវចូលរួមយ៉ាងសកម្មជាចាំបាច់ក្នុងដំណើរការនេះដែរ ដោយគួរតែបង្កើតក្រុមការងារ ហើយបន្តធ្វើការដោយគ្មានយោគយល់ចំពោះការចោទប្រកាន់លើអំពើពុករលួយនេះ បើទោះជាប្រព្រឹត្តឡើងដោយបុគ្គលិកកម្ពុជា ឬបុគ្គលិកអន្តរជាតិក៏ដោយ ។ បន្ថែមលើការបង្កើតគណៈកម្មាធិការចម្រុះបដើម្បីត្រួតពិនិត្យលើការចោទពីបទប្រព្រឹត្តអំពើអាក្រក់បែបនេះ អ្នកផ្តល់ជំនួយ គួរតែទទូចឲ្យមានការកែតម្រូវជាបន្ទាន់ចំពោះការទទួលខុសទាំងឡាយដែលកើតមាន ។ លើសពីនេះទៀត អ្នកផ្តល់ជំនួយគួរតែបញ្ជាក់ឲ្យច្បាស់ដល់ទាំងមន្ត្រីខាងអង្គការសហប្រជាជាតិ និងខាងរដ្ឋាភិបាលថា បញ្ហាពុករលួយមិនមែនជាកលល្បិចសម្រាប់បំភាន់នោះទេ ។ វាជារឿងមួយក្នុងចំណោម "វិធីប្រើប្រាស់ជំនួយដើម្បីបញ្ចប់អំពើពុករលួយ" មួយចំនួន ប្រសិនបើវាមិនបានដោះស្រាយភ្លាមៗហើយលទ្ធផលនឹងប៉ះពាល់មិនត្រឹមតែតុលាការនោះទេ ។ រដ្ឋាភិបាលលោកខាងលិចមិនអាចដោះស្រាយបញ្ហាដូចនេះតែម្នាក់ឯងបានឡើយ ។ ប្រទេសជប៉ុនត្រូវតែប្រើតួនាទីនាំមុខរបស់ខ្លួនដែលជាអ្នកផ្តល់ជំនួយសំខាន់ដល់តុលាការនេះ ហើយប្រទេសចិន និងប្រទេសនៅអាស៊ីអាគ្នេយ៍មិនគួរអនុញ្ញាតឲ្យរឿងនេះកើតឡើងដោយមិនយកចិត្តទុកដាក់ដូចដែលខ្លួនតែងតែមិនអើពើនៅអតីតកាលនោះទេ ។

ការយករឿងអំពើពុករលួយជារឿងនាំមុខ វាជាដំហរមួយផ្តល់ភាពគ្រោះថ្នាក់ ។ ការតវ៉ាច្រើនពីរឿងនេះធ្វើឲ្យមានការប៉ះពាល់ដល់ការពន្យារពេលម្តងទៀត ឬការបញ្ឈប់តុលាការតែម្តង ។ តែទោះជាយ៉ាងណាក៏ដោយ ក៏អំពើពុករលួយជារឿងមួយមិនគួរមិនយកចិត្តទុកដាក់នោះទេ ។ អង្គជំនុំ

*ជម្រះមិនអាចធ្វើឲ្យជនរងគ្រោះពីរបបកម្ពុជាប្រជាធិបតេយ្យបៀមទុកការរំលោភបំពានដែលខ្លួនធ្លាប់រងទទួលនោះទេ ។ អ្វីដែលតុលាការនេះអាចធ្វើ គឺផ្ដល់នូវការវិនិច្ឆ័យដោយយុត្តិធម៌ និងធ្វើឲ្យប្រព័ន្ធច្បាប់មួយប្រសើរឡើង ដែលនឹងការពារសិទ្ធិប្រជាជនកម្ពុជានាពេលអនាគត ។ នេះជាបទដ្ឋានមួយដែលតុលាការនេះគួរតែប្រកាន់យក ។*

**ចន ឆរឆីអារី** (John D. Ciorciar)

**ទីប្រឹក្សាច្បាប់មជ្ឈមណ្ឌលឯកសារកម្ពុជា**

**ប្រែសម្រួលជាភាសាខ្មែរដោយ ព្រុំ ផល្លា**

**មជ្ឈមណ្ឌលឯកសារកម្ពុជា**